# បញ្ឈប់កំណើតរហូតគឺ

## ចងបំពង់បង្ហូរមេជីវិត

### ១. តើអ្វីទៅការចងបំពង់មេជីវិត?

ជាមធ្យោបាយបញ្ឈប់កំណើតរហូតចំពោះបុរស ។

### ២. តើមធ្យោបាយនេះសម្រាប់អ្នកណា?

មធ្យោបាយនេះសមស្របសម្រាប់បុរសណាដែលគ្រួសារគាត់មានកូនចាប់ពី២-៣ឡើង ទៅលែងចង់បានកូនទៀត និងមានការព្រមព្រៀងគ្នារវាងប្តី និងប្រពន្ធ ។

### ៣. តើអ្នកអាចទទួលយកមធ្យោបាយនេះនៅពេលណា?

អ្នកអាចទទួលយកមធ្យោបាយនេះបានគ្រប់ពេលទាំងអស់ ។

### ៤. តើការចងបំពង់មេជីវិតផ្តល់ផលប្រយោជន៍ដូចម្តេចខ្លះ?

- ប្រពន្ធរបស់អ្នកមិនចាំបាច់ប្រើមធ្យោបាយពន្យារកំណើតណាមួយទៀតឡើយ
- មិនព្រួយបារម្ភពីការមានកូនទៀតឡើយ
- ប្រពន្ធអ្នកមិនចាំបាច់ចំណាយលុយកាក់សម្រាប់ការសម្រាលកូនទេ
- ចំណេញពេលវេលាសម្រាប់ធ្វើការរកប្រាក់ចំណូល

### ៥. តើការចងបំពង់មេជីវិតធ្វើឡើងយ៉ាងដូចម្តេច?

ការចងបំពង់មេជីវិតធ្វើឡើងតាមរយៈការចោះរន្ធតូចមួយនៅលើស្បែកពងស្វាសរបស់បុរសដោយប្រើថ្នាំស្ពឹកនៅនឹងកន្លែង មិនមានការឈឺចាប់ ហើយប្រើរយៈពេលប្រហែល១៥ទៅ ៣០នាទីប៉ុណ្ណោះ ដោយមិនចាំបាច់សម្រាកនៅក្នុងមន្ទីរពេទ្យឡើយ ។

បំពង់មេជីវិតដែល
ត្រូវចោះចង គឺនៅត្រង់នេះ



### ៦. បន្ទាប់ពីចងបំពង់មេជីវិតរួច...

- អ្នកនៅតែអាចធ្វើការបានដូចធម្មតា
- អ្នកនៅតែអាចបញ្ចេញទឹកកាមបានដដែល តែប្រពន្ធរបស់អ្នកមិនអាចមានផ្ទៃពោះទេ
- អ្នកនៅតែមានសុខភាព និងនៅតែអាចរួមភេទបានដូចធម្មតា ជាពិសេសមិនបន្ថយភាពរឹងនៃប្រដាប់ភេទឡើយ

**ចំនុចគួរយល់ដឹង:**

ការចងប្រើរយៈពេលខ្លី និងមិនមានការឈឺចាប់ ។បន្ទាប់ពីចងរួចរយៈពេលខ្លី អ្នកនឹងមានកំលាំងគ្រប់គ្រាន់ ហើយអាចត្រឡប់ទៅផ្ទះដោយខ្លួនឯង ។ មុខរបួសនឹងជាសះស្បើយក្នុងរយៈពេល២ឬ៣ថ្ងៃក្រោយមក ។ បន្ទាប់ពីចងហើយ អ្នកត្រូវប្រើស្រោមអនាម័យរាល់ពេលរួមភេទចំនួន៣ខែ ។ វិធីនេះមានអត្រាបរាជ័យតិចតួចបំផុត ។ ការចងមិនបន្ថយភាពរឹងនៃប្រដាប់ភេទឡើយ ។

RHAC អង្គការថែទាំសុខភាពគ្រួសារកម្ពុជា (រ៉ាក់)

# ដំណឹងពិសេស

គ្លីនិក រ៉ាក់ ខេត្តកំពង់ស្ពឺមានផ្តល់នូវសេវាកម្មបញ្ឈប់កំណើត :

**សម្រាប់បុរសដោយឥតគិតថ្លៃរយៈពេល១ខែ**

# ចងបំពង់បង្ហូរមេជីវិត ដោយឥតគិតថ្លៃ

**ចាប់ពីថ្ងៃទី០១ ខែមីនា**

**រហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១២**

**សូមកុំឱ្យឱកាសដ៏ល្អនេះ កន្លងផុតឱ្យសោះ**

នៅគ្លីនិក រ៉ាក់ ភូមិស្ពោរទី១ ឃុំរកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ
ទូរស័ព្ទ :០២៥ ៩៨៧ ១៤៥

អ្នកអាចរកមធ្យោបាយពន្យារកំណើតដទៃទៀតនៅគ្លីនិក រ៉ាក់ : (ថ្នាំលេប ថ្នាំចាក់ កងដាក់ដៃ កងដាក់ក្នុងស្បូន ស្រោមអនាម័យ) បញ្ឈប់កំណើតរហូត (ចងដៃស្បូន)

USAID ជំនួយពីពលរដ្ឋអាមេរិក រួមគ្នាដើម្បីសុខភាពល្អ RHAC

# ប្លង់គ្លីនិក "រ៉ាក់" (ខេត្តកំពង់ស្ពឺ)

**ថ្ងៃធ្វើការ : អាទិត្យ ដល់ សុក្រ ព្រឹកពីម៉ោង ៨:០០ ដល់១២:០០, ល្ងាចពីម៉ោង ១:០០ ដល់៥:០០**




អាសយដ្ឋាន : ភូមិស្នោរទី១ ឃុំរកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ

ទូរស័ព្ទលេខ : ០២៥ ៩៨៧ ១៤៥

**ឧបត្ថម្ភដោយ :** USAID ជំនួយពីប្រជាជនអាមេរិក រួមគ្នាដើម្បីសុខភាពល្អ RHAC